**សុន្ទរកថារបស់លោក Jeff Daigle ភារធារីស្ថានទូតសហរដ្ឋអាមេរិក ក្នុងពិធីអបអរទិវាសិទ្ធិមនុស្សអន្តរជាតិលើកទី៦៤**

ជំរាបសួរភ្ញៀវកិត្តិយស ដៃគូ និងមេដឹកនាំសង្គមស៊ីវិល។ ខ្ញុំមានសេចក្តីរីករាយក្នុងការចូលរួមដើរដង្ហែជាមួយលោកអ្នក នៅថ្ងៃនេះ ដើម្បីអបអរទិវាសិទ្ធិមនុស្សអន្តរជាតិលើកទី៦៤។

ជារៀងរាល់ឆ្នាំ នាថ្ងៃទី១០ ខែធ្នូ យើងទាំងអស់គ្នាតែងតែប្រារព្ធពិធីរំលឹកខួបនៃការអនុម័តសេចក្តីថ្លែងការណ៍ជាសាកលស្តីពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ។ ក្នុងការអនុម័តសេចក្តីថ្លែងការណ៍នេះ សហរដ្ឋអាមេរិក និងរដ្ឋាភិបាលនានានៅលើសាកលលោកសុទ្ធតែបានអះអាងថា មនុស្សគ្រប់រូបត្រូវបានផ្តល់នូវសិទ្ធិនានា ដែលមិនអាចកាត់ផ្តាច់បានពីកំណើតមក។

ថ្ងៃនេះ យើងបន្តកិច្ចខិតខំប្រឹងប្រែងបន្តទៀត ដើម្បីធ្វើឲ្យសិទ្ធិមនុស្សក្លាយជាការពិតសំរាប់មនុស្សគ្រប់រូបមិនថាពួកគេជានរណា ឬរស់នៅទីកន្លែងណានោះឡើយ។ សិទ្ធិមនុស្សរួមមានសិទ្ធិក្នុងការបញ្ចេញមតិ សិទ្ធិក្នុងការទិទៀន សិទ្ធិក្នុងការប្រមូលផ្តុំគ្នា និងសិទ្ធិក្នុងការប្រតិបត្តិជំនឿសាសនារបស់គេ។

រដ្ឋទាំងឡាយមានកាតព្វកិច្ចក្រោមច្បាប់អន្តរជាតិ ក្នុងការគោរពសេរីភាពជាមូលដ្ឋានទាំងនេះ មិនថាសិទ្ធិទាំងនោះ ត្រូវបានអនុវត្តក្នុងលក្ខណៈបែបណាក៏ដោយ។ រដ្ឋាភិបាលទាំងឡាយចាំបាច់ត្រូវធានាថា ប្រព័ន្ធយុត្តិធម៌ត្រូវមានភាពឯករាជ្យ ដាច់ចេញពីការជ្រៀតជ្រែក របស់អ្នកនយោបាយ ដើម្បីធានាថាសិទ្ធិទាំងនេះត្រូវបានគោរព។

នៅសហរដ្ឋអាមេរិក យើងខិតខំការពារសិទ្ធិទាំងនេះ ហើយការលើកកំពស់សិទ្ធិធ្វើជាធាតុដ៏ចំបងមួយក្នុងគោលនយោបាយការបរទេសរបស់ខ្លួន។ ការការពារសិទ្ធមនុស្សមានសារៈសំខាន់ណាស់សំរាប់នីតិរដ្ឋដ៏រឹងមាំ សន្តិសុខរបស់ជនស៊ីវិល ការអភិវឌ្ឍសេដ្ឋកិច្ច និងសន្តិភាពយូរអង្វែង។

នេះគឺជាសារគន្លឹះមួយរបស់លោកប្រធានាធិបតី បារ៉ាក់ អូបាម៉ា ក្នុងកំឡុងទស្សនកិច្ចមកកាន់ព្រះរាជាណាចក្រកម្ពុជា កាលពីខែមុននេះ ដោយពេលនោះ លោកបានជម្រុញឲ្យមានភាពជឿនលឿនលើបញ្ហាទាំងនេះ និងបានសង្កត់ធ្ងន់ថា ក្តីសង្ឃឹម

សម្រាប់ប្រជាជនកម្ពុជានឹងអាចមានទៅបាន លុះត្រាតែសិទ្ធិមនុស្សត្រូវបានគោរព យ៉ាងពេញលេញ ហើយសម្លេងរបស់ពួកគេទទួលបានការយកចិត្តទុកដាក់។

អង្គការសង្គមស៊ីវិលជួយធានា នូវភាពជាតំណាងឲ្យសម្លេងប្រជាពលរដ្ឋ ដោយការពារអ្នកដែលត្រូវបានគេបំបិទសំលេង ហើយអង្គការនេះជួយបំពេញបន្ថែម ដល់កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការស្វែងរកដំណោះស្រាយថ្មីៗចំពោះបញ្ហាដែលមានភាពស្មុគស្មាញ។ ប្រវត្តិសាស្ត្របង្ហាញពីសារៈសំខាន់ របស់អង្គការសង្គមស៊ីវិលក្នុងការនាំមកនូវសហាគមន៍ប្រកប ដោយភាពរស់រវើក ទាំងក្នុង និងក្រៅប្រទេស ។

ដូច្នេះ សហរដ្ឋអាមេរិកគាំទ្រអ្នកគាំពារសិទ្ធិមនុស្ស និងធ្វើការជាមួយសកម្មជន និងអង្គការសង្គមស៊ីវិលទាំងឡាយ ក្នុងព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាក្នុងពិភពលោក ដើម្បីកសាងសមត្ថភាពជនកម្ពុជា ដើម្បីលើកស្ទួយសិទ្ធិមនុស្សជាមូលដ្ឋាន។ លោកស្រី ហ៊ីឡារី ក្លីនតុន រដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិក បានមានប្រសាសន៍ថា "របៀបវារៈសិទ្ធិមនុស្សរបស់យើងក្នុងសតវត្សទី២១ គឺការធ្វើឲ្យការគោរពសិទ្ធិមនុស្សក្លាយជាការពិត។ ទិវាសិទ្ធិមនុស្សជានិមិត្តរូប នៃការបន្តតស៊ូឲ្យសិទ្ធិមនុស្សមានលក្ខណៈជាសាកលលោកពិតៗ សំរាប់មនុស្សទាំងអស់ ដោយមិនគិតពីពណ៌សម្បុរ  សញ្ជាតិ ជាតិសាសន៍ និន្នាការផ្លូវភេទ ពិការភាព ជាតិពន្ធុ ឬសាសនានោះឡើយ។

នៅកម្ពុជា យើងអាចសម្រេចគោលដៅនេះបានតែតាមរយៈការចូលរួមយ៉ាងសកម្មពីសំណាក់ប្រជាជនកម្ពុជាគ្រប់រូប។ ដោយធ្វើការពង្រឹង និងការពារសិទ្ធិមនុស្ស អ្នកទាំងអស់គ្នាកំពុងកសាងកម្ពុជាអោយបានរឹងមាំ ដែលធានានូវអនាគតដ៏ភ្លឺស្វាងសម្រាប់មនុស្សជំនាន់ក្រោយ។ សូមអរគុណ។

**សួនសេរីភាព ក្រុងភ្នំពេញ | ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១២**